PARLIAMENTARY CENTRE OF ASIA
Strengthening Parliamentary Capacity

# ឯកសារស្រាវជ្រាវសង្ខេប

## គណៈកម្មការទី៣ នៃរដ្ឋសភា

# អភិបាលកិច្ចព្រៃកោងកាង និង បទពិសោធន៍ល្អៗនៅកម្ពុជា ថៃ និងឥណ្ឌូនេស៊ី

ខែមិនា ឆ្នាំ២០២៤

អ្នកស្រាវជ្រាវ៖ លោកស្រី រស់ បណ្ដែត
លោក ញៀប សិលា

# កំណត់សម្គាល់

មជ្ឈមណ្ឌលសភាអាស៊ី (ម.ស.អ) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាទាំងឡាយ តាមការស្នើសុំរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញសភា និងអគ្គលេខាធិការដ្ឋាន តាមរយៈការផ្តល់ជូននូវការបណ្តុះបណ្តាល និងការស្រាវជ្រាវជាច្រើន ស្តីពីបញ្ហាសំខាន់ៗដែលកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌលសភាខេត្ត/ក្រុង ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់មជ្ឈមណ្ឌលសភាអាស៊ី សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាឱ្យបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីមជ្ឈមណ្ឌល។

រក្សាសិទ្ធិ ឆ្នាំ២០២៤ មជ្ឈមណ្ឌលសភាអាស៊ី (ម.ស.អ)។

# មាតិកា

សេចក្តីសង្ខេប ........ iii
១. សេចក្តីផ្តើម ........ 1
២. វិធីសាស្ត្រស្រាវជ្រាវ ........ 1
៣. ទីតាំងភូមិសាស្ត្រ ........ 2
៤. និន្នាការ និងកត្តាជម្រុញដល់ការបាត់បង់ព្រៃកោងកាង ........ 3
៤.១ និន្នាការព្រៃកោងកាង ........ 3
៤.២ កត្តាជម្រុញដល់ការបាត់បង់ព្រៃកោងកាង ........ 5
៥. ប្រភេទជម្លោះ និងការរំលោភបំពានលើសិទ្ធិកាន់កាប់ព្រៃកោងកាង ........ 6
៦. អភិបាលកិច្ចព្រៃកោងកាង ........ 6
៦.១ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ........ 6
៦.២ បញ្ហាប្រឈមផ្នែកអភិបាលកិច្ច ........ 13
៧. សេចក្តីសន្និដ្ឋាន និងបទពិសោធន៍ល្អៗ ........ 16
ឯកសារយោង ........ 18
ឧបសម្ព័ន្ធ ........ 22

# សេចក្តីសង្ខេប

នៅតំបន់អាស៊ីអាគ្នេយ៍ គេទទួលស្គាល់ថា ព្រៃកោងកាងជាធនធានដ៏មានសារៈសំខាន់ក្នុងការជួយគាំទ្រដល់ប្រព័ន្ធអេកូឡូស៊ីទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ជួយលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងជួយការពារតំបន់ឆ្នេរសមុទ្រ។ ទោះបីជា៣៣%នៃគម្របព្រៃកោងកាងសរុបនៅលើពិភពលោក ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយមួយភាគប្រាំ (២០%) ស្ថិតនៅក្នុងប្រទេសឥណ្ឌូនេស៊ីក៏ដោយ ក៏អាស៊ីអាគ្នេយ៍នៅតែជាតំបន់ដែលជួបប្រទះនឹងការបាត់បង់ព្រៃកោងកាងដ៏ច្រើនសម្បើមបំផុត។ ចំនុចនេះឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាជាប្រព័ន្ធនៃអភិបាលកិច្ចព្រៃកោងកាងក្នុងតំបន់ ដែលគួរដោះស្រាយជាបន្ទាន់។

ឯកសារស្រាវជ្រាវនេះ បានមកពីការសិក្សាលើឯកសារដែលមានស្រាប់ ដើម្បីកំណត់ពីបញ្ហាប្រឈមចម្បងៗចំពោះអភិបាលកិច្ចព្រៃកោងកាង ដែលនាំឱ្យមានជម្លោះលើសិទ្ធិកាន់កាប់និងការបាត់បង់ព្រៃកោងកាងនៅកម្ពុជា ថៃ និងឥណ្ឌូនេស៊ី ដើម្បីទាញយកបទពិសោធន៍ល្អៗជាគំរូសម្រាប់អភិបាលកិច្ចព្រៃកោងកាងប្រកបដោយចីរភាពនៅក្នុងតំបន់។

របកគំហើញពីឯកសារស្រាវជ្រាវនេះបង្ហាញថា កត្តាចម្បងដែលជំរុញឱ្យមានការបាត់បង់ព្រៃកោងកាង និងបង្កជាជម្លោះនៅក្នុងប្រទេសទាំងបីរួមមាន៖ ភាពមិនច្បាស់លាស់លើសិទ្ធិកាន់កាប់និងផែនការប្រើប្រាស់ព្រៃកោងកាង ការអនុវត្តច្បាប់នៅមានកម្រិត ការសម្របសម្រួលអន្តរវិស័យពុំសូវមានប្រសិទ្ធភាព និងកង្វះការចូលរួមពីសហគមន៍។ ឯកសារស្រាវជ្រាវនេះបានបង្ហាញពីបទពិសោធន៍ល្អៗមួយចំនួនពីប្រទេសទាំងបីដែលអាចជាធាតុចូលសម្រាប់ការលើកកម្ពស់កិច្ចការពារព្រៃកោងកាង ក្នុងតំបន់អាស៊ីអាគ្នេយ៍ប្រកបដោយប្រសិទ្ធភាព។

## ១. សេចក្ដីផ្ដើម

ព្រៃកោងកាងគឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ ដែលជួយទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានរស់នៅរបស់មនុស្ស។ ព្រៃកោងកាងសរុបនៅលើពិភពលោកមានប្រមាណ ១៤,៧៣លានហិកតាក្នុងឆ្នាំ២០២០ ដែលស្ថិតនៅក្នុងបណ្ដាប្រទេសចំនួន១១៣។ គម្របព្រៃកោងកាងធំបំផុត គឺស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ (៣៣%) ដែលក្នុងនោះប្រទេសឥណ្ឌូនេស៊ីមានផ្ទៃដីព្រៃកោងកាងធំជាងគេ ពោលគឺមួយភាគប្រាំនៃចំនួនព្រៃកោងកាងសរុបនៅក្នុងពិភពលោក [១]។ ៣០%នៃផលនេសាទត្រី និងស្ទើរតែ ១០០%នៃផលនេសាទបង្គា នៅតំបន់អាស៊ីអាគ្នេយ៍ គឺជាការរួមចំណែករបស់ព្រៃកោងកាង [២]។ ព្រៃកោងកាង អាចស្រូបយកកាបូនប្រមាណ៣៥០លានមេហ្កាក្រាម នៅទូទាំងពិភពលោក [១]។ ព្រៃកោងកាង ក៏អាចការពារការខូចខាតទ្រព្យសម្បត្តិជាង៦៥ពាន់លានដុល្លារ ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ និងជួយកាត់បន្ថយហានិភ័យទឹកជំនន់ដល់ប្រជាពលរដ្ឋ ១៥លាននាក់ជារៀងរាល់ឆ្នាំផងដែរ [៣]។

ទោះបីមានគម្របព្រៃកោងកាងយ៉ាងច្រើនបំផុត តែតំបន់អាស៊ីអាគ្នេយ៍ក៏កំពុងជួបប្រទះនឹងការបាត់បង់ព្រៃកោងកាង [១]។ កត្តាជម្រុញនៃការបាត់បង់ព្រៃកោងកាងនៅអាស៊ីអាគ្នេយ៍ ត្រូវបានផ្សារភ្ជាប់ទៅនឹងកត្តាមនុស្ស និងកត្តាធម្មជាតិ។ ប៉ុន្តែកត្តាមនុស្ស នៅតែជាកត្តាចម្បង ដែលបង្កឱ្យមានជម្លោះលើសិទ្ធិកាន់កាប់ដីធ្លី អំពើហិង្សា និងការបំផ្លាញប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងនៅតាមតំបន់ឆ្នេរ [១]។ កត្តាមនុស្សដែលរួមមាន ការកាប់ឆ្ការព្រៃកោងកាងសម្រាប់វិស័យកសិកម្ម វារីវប្បកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បញ្ជាក់ពីបញ្ហាជាប្រព័ន្ធក្នុងការគ្រប់គ្រងព្រៃកោងកាងនៅតំបន់អាស៊ីអាគ្នេយ៍ ដែលចាំបាច់ត្រូវដោះស្រាយ [៤]។

ឯកសារស្រាវជ្រាវនេះ ជាការសិក្សាលើឯកសារដែលមានស្រាប់ ដើម្បីកំណត់រកនូវបញ្ហាប្រឈមចម្បងៗចំពោះអភិបាលកិច្ចព្រៃកោងកាង ដែលនាំឱ្យមានជម្លោះលើសិទ្ធិកាន់កាប់ដីធ្លី និងការបាត់បង់ព្រៃកោងកាងនៅកម្ពុជា ថៃ និងឥណ្ឌូនេ-ស៊ី។ ការសិក្សានេះក៏ដើម្បីរកមើល និងបង្ហាញពីបទពិសោធន៍ល្អៗសម្រាប់អភិបាលកិច្ចព្រៃកោងកាងប្រកបដោយប្រសិទ្ធភាព និងសមធម៌ផងដែរ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការផលិតឯកសារស្រាវជ្រាវនេះបានប្រើប្រាស់ទិន្នន័យដែលមានស្រាប់ ដោយរួមមាន សំណុំទិន្នន័យ របាយការណ៍ អត្ថបទទិនានុប្បវត្តិ ក្របខ័ណ្ឌច្បាប់ និងឯកសារគោលនយោបាយនានារបស់រដ្ឋាភិបាលកម្ពុជា ថៃ និងឥណ្ឌូនេស៊ី អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ដើម្បីឆ្លើយតបទៅនឹងសំណួរនៃការស្រាវជ្រាវនេះ។ ដើម្បីសំយោគព័ត៌មានអំពីនិន្នាការនៃការបាត់បង់ព្រៃកោងកាងនៅប្រទេសទាំងបី ការស្រាវជ្រាវនេះក៏ពឹងផ្អែកលើបណ្ដុំទិន្នន័យរបស់អង្គការឃ្លាំមើលព្រៃកោងកាងសកលឆ្នាំ២០២២ សំណុំទិន្នន័យរបស់អង្គការ FAO ឆ្នាំ២០០៧ និងការវិភាគរបស់ Veettil and Quang ឆ្នាំ២០១៩ របស់ Pumijumnong ឆ្នាំ២០១៤ និងរបស់ Arifanti et al. ឆ្នាំ២០២២។

## ៣. ទីតាំងភូមិសាស្ត្រ

តំបន់អាស៊ីអាគ្នេយ៍ មានព្រៃកោងកាងសរុបប្រមាណ៣៣%នៃគម្របព្រៃកោងកាងនៅលើពិភពលោក។ យោងតាមទិន្នន័យរបស់អង្គការឃ្លាំមើលព្រៃកោងកាងសកល ក្នុងឆ្នាំ២០២០ប្រទេសឥណ្ឌូនេស៊ី ជាប្រទេសនាំមុខគេ ដែលមានគម្របព្រៃកោងកាងច្រើនបំផុត ខណៈប្រទេសថៃ និងកម្ពុជា ជាប់ចំណាត់ថ្នាក់ទី៥ និងទី៧រៀងគ្នានៅក្នុងតំបន់ [១,៥]។




*រូបភាពទី ១៖ របាយភូមិសាស្ត្រនៃព្រៃកោងកាងក្នុងប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី [៥,១១]*

វិសាលភាពព្រៃកោងកាងដ៏ធំធេងនេះ អាចទាក់ទងទៅនឹងអំណោយផលធម្មជាតិនៃទីតាំងភូមិសាស្ត្ររបស់បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ គួរកត់សម្គាល់ផងដែរថា ព្រៃកោងកាងនៅប្រទេសឥណ្ឌូនេស៊ី ដែលមានទំហំដល់ទៅមួយភាគប្រាំនៃព្រៃកោងកាងពិភពលោក គឺស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រប្រវែង ៩៥.១៨១ គីឡូម៉ែត្រ ក្នុងបណ្តាកោះសំខាន់ៗចំនួន៥ ដូចជា យ៉ាវ៉ា សូម៉ាត្រា កាលីម៉ាន់តាន់ សូឡាវេស៊ី និងប៉ាពូ ក្នុងចំណោមកោះជាង ១៧.៥០៤ [៦,៧]។ នៅប្រទេសកម្ពុជា ព្រៃកោងកាង លាតសន្ធឹងតាមបណ្តោយឆ្នេរនៃខេត្តជាប់មាត់សមុទ្រចំនួនបួនសំខាន់ៗ គឺខេត្តកោះកុង ព្រះសីហនុ កំពត និងកែប ដែលស្ថិតនៅឆ្នេរភាគពាយ័ព្យនៃឈូងសមុទ្រថៃប្រវែងសរុប៤៣៤គីឡូម៉ែត្រ [៨]។ នៅប្រទេសថៃ ប្រហែល៨០%នៃព្រៃកោងកាងស្ថិតនៅតាមបណ្តោយឆ្នេរអានដាមាន់ ប្រវែងសរុប៩៣៧គីឡូម៉ែត្រនៅក្នុងមហាសមុទ្រឥណ្ឌា ខណៈព្រៃកោងកាងដែលនៅសល់ គឺស្ថិតនៅតាមបណ្តោយឈូងសមុទ្រថៃដែលមានប្រវែង ១.៨៧៨គីឡូម៉ែត្រ [៩,១០]។

## ៤. និន្នាការ និងកត្តាជម្រុញដល់ការបាត់បង់ព្រៃកោងកាង

### ៤.១ និន្នាការព្រៃកោងកាង

ប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី មានប្រភេទពូជព្រៃកោងកាងចម្រុះ។ គេបានរកឃើញថា ប្រទេសកម្ពុជាមានពូជព្រៃកោងកាងចំនួន២៩ប្រភេទ ថៃមានចំនួន៣៥ប្រភេទ និងឥណ្ឌូនេស៊ីមានចំនួន៤៧ប្រភេទ។ គួរកត់សម្គាល់ថា អង្គការ អាយយូស៊ីអិន (IUCN) បានសិក្សាឃើញថា ព្រៃកោងកាងពីរប្រភេទនៅប្រទេសថៃ និងប្រាំប្រភេទនៅប្រទេសឥណ្ឌូនេស៊ី កំពុងជិតផុតពូជ [៥]។

*តារាងទី ១៖ វិសាលភាពព្រៃកោងកាងនៅកម្ពុជា ថៃ និងឥណ្ឌូនេស៊ី ពីប្រភពផ្សេងៗ [៥,១២,១៣,១៤,១៥]*

| | ឯកសារយោង | ឆ្នាំ | ផ្ទៃដី (ហិកតា) |
|---|---|---|---|
| កម្ពុជា | FAO (២០០៧) | ២០០៥ | ៦៩.២០០ |
| | Veettil and Quang (២០១៩) | ២០១៦ | ៥១.៦០៣ |
| | MoE(២០២០) | ២០១៨ | ៥៧.០៥៣ |
| | GMW (២០២២) | ២០២០ | ៦២.៦៩១ |
| ថៃ | FAO (២០០៧) | ២០០៥ | ២២៩.៦១៨ |
| | Pumijumnong (២០១៤) | ២០០៧ | ២២៩.៦១៨ |
| | GMW (២០២២) | ២០២០ | ២៥២.៧៩៨ |
| ឥណ្ឌូនេស៊ី | FAO (២០០៧) | ២០០៥ | ២.៩០០.០០០ |
| | GMW (២០២២) | ២០២០ | ២.៩៥៣.៣៩៨ |

មានការសិក្សាឃើញខុសៗគ្នាពីវិសាលភាពព្រៃកោងកាងនៅប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី។ ទោះបីជាយ៉ាងណាក៏ដោយ យោងតាមអង្គការឃ្លាំមើលព្រៃកោងកាងសកលឆ្នាំ២០២២ បានប៉ាន់ស្មានថា ផ្ទៃដីព្រៃកោងកាង មានចំនួន ៦២.៦៩១ហិកតានៅកម្ពុជា ២៥២.៧៩៨ហិកតានៅថៃ និង២,៩លានហិកតានៅឥណ្ឌូនេស៊ី ដែលក្នុងនោះ ៦៥%, ៦,២៩%, និង២៥% ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសនីមួយៗ [៥] ។

កាលពីអតីតកាល ព្រៃកោងកាងនៅប្រទេសទាំងបីនេះត្រូវបានបំផ្លិចបំផ្លាញយ៉ាងខ្លាំង ប៉ុន្តែក្នុងឆ្នាំខ្លះវិសាលភាពនៃការបាត់បង់ព្រៃកោងកាងក៏មានការថយចុះគួរឱ្យចាប់អារម្មណ៍។

ឧទាហរណ៍ យោងតាមលោក Veettil and Quang (២០១៩) ប្រទេសកម្ពុជាបានបាត់បង់ព្រៃកោងកាងចំនួន ៣៦.៨១០ ហិកតា នៅចន្លោះឆ្នាំ ១៩៨៩ និងឆ្នាំ២០១៦/២០១៧។ ការបាត់បង់ព្រៃកោងកាងដ៏ច្រើនបំផុតនៅប្រទេសកម្ពុជា បានកើតឡើងនៅចន្លោះឆ្នាំ១៩៨៩ ដល់ឆ្នាំ ១៩៩៤ ដោយអត្រា ១.៩៩៤ហិកតាជាមធ្យមក្នុងមួយឆ្នាំ។ អត្រានេះបានថយចុះបន្តិចនៅចន្លោះឆ្នាំ១៩៩៤ ដល់ ២០០៩ ជាមួយនឹងអត្រា ១.៣០១ហិកតាជាមធ្យមក្នុងមួយឆ្នាំ។ អត្រានៃការបាត់បង់ បានបន្តធ្លាក់ចុះនៅចន្លោះឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៧ ជាមួយនឹងអត្រាត្រឹមតែ ៩១៦ហិកតាជាមធ្យមក្នុងមួយឆ្នាំ [១៤]។




*រូបភាពទី ២៖ អត្រាបាត់បង់ព្រៃកោងកាងជាមធ្យមក្នុងមួយឆ្នាំនៅកម្ពុជា ថៃ និងឥណ្ឌូនេស៊ី [១៣,១៤,១៥]*

ប្រទេសថៃ បានបាត់បង់ព្រៃកោងកាងចំនួន ១៤២.៧៣៧ ហត នៅចន្លោះឆ្នាំ១៩៦១ ដល់ឆ្នាំ២០០៧។ ការបាត់បង់ព្រៃកោងកាងដ៏ច្រើននៅប្រទេសថៃ បានកើតឡើងនៅចន្លោះឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៨៦ ជាមួយនឹងអត្រា ៧.០៣៧ហិកតាជាមធ្យមក្នុងមួយឆ្នាំ។ អំឡុងពេលនោះ ការបាត់បង់ព្រៃកោងកាងដ៏សម្បើម គឺកើតឡើងនៅតាមបណ្ដោយឆ្នេរសមុទ្រភាគខាងលិចនៃតំបន់ភាគខាងត្បូង និងតំបន់ភាគខាងកើត ព្រមទាំងឆ្នេរសមុទ្រខាងកើតនៃតំបន់ភាគខាងត្បូង និងតំបន់ភាគកណ្ដាល។ អត្រានៃការបាត់បង់ព្រៃកោងកាង បានថយចុះមកត្រឹមតែ ២.៨៥៨ហិកតាជាមធ្យមក្នុងមួយឆ្នាំនៅចន្លោះឆ្នាំ១៩៨៦-១៩៩៦ មុនពេលអត្រានេះ បានបន្តកើនឡើងដល់ ៥.៦១៥ហិកតាក្នុងមួយឆ្នាំនៅចន្លោះឆ្នាំ ១៩៩៦-២០០៧ [១៥]។

ការបាត់បង់ព្រៃកោងកាងសរុបនៅប្រទេសឥណ្ឌូនេស៊ីមានចំនួន១,៣លានហិកតា នៅចន្លោះឆ្នាំ១៩៨០ ដល់ឆ្នាំ ២០០៥។ ខណៈអត្រាបាត់បង់ព្រៃកោងកាងជាមធ្យមនៅប្រទេសឥណ្ឌូនេស៊ីមានកម្រិតខ្ពស់ ក្នុងចំនួនដល់ទៅ ៧០.០០០ហិកតាក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៨០-១៩៩០។ បន្ទាប់មក អត្រានេះបានធ្លាក់ចុះមកត្រឹម ៣៥.០០០ហិក-តាក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩០-២០០០ ហើយបានបន្តកើនឡើងបន្តិចទៅដល់ ៥០.០០០ ហិកតាក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០០០-២០០៥ [១៣]។

ទិន្នន័យចុងក្រោយ របស់អង្គការឃ្លាំមើលព្រៃកោងកាងសកលឆ្នាំ២០២២ បានបង្ហាញពីនិន្នាការវិជ្ជមាន ចំពោះការកើនឡើងនៃព្រៃកោងកាងនៅប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ីចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ២០១០។ ចាប់ពីឆ្នាំ២០០៨-២០០៩មក អត្រានៃការបាត់បង់ព្រៃកោងកាងប្រចាំឆ្នាំរបស់ប្រទេសទាំងបី បានចាប់ផ្ដើមធ្លាក់ចុះបន្តិចម្ដងៗ ហើយនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ២០១០ អត្រាបាត់បង់នេះ បានធ្លាក់ចុះក្រោមសូន្យ ពោលគឺបង្ហាញថាប្រទេសទាំងបីនេះ បានស្ដារឡើងវិញនូវគម្របព្រៃកោងកាងរបស់ខ្លួនបានកាន់តែប្រសើរ។ ជាឧទាហរណ៍ ព្រៃកោងកាងនៅប្រទេសកម្ពុជា បានកើនឡើងវិញចាប់ពីឆ្នាំ២០១៦-២០១៧ នៅប្រទេសថៃចាប់ពីឆ្នាំ២០០៩-២០១០ និងនៅប្រទេសឥណ្ឌូនេស៊ី ចាប់ពីឆ្នាំ ២០១៧-២០១៨ (សូមមើលរូបភាពទី៣) ។ និន្នាការវិជ្ជមាននេះ អាចជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងការពារ និងស្ដារឡើងវិញរបស់ប្រទេសនីមួយៗ [៥,១៦]។




*រូបភាពទី ៣៖ អត្រាបាត់បង់ព្រៃកោងកាងប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី ពីឆ្នាំ១៩៩៦-២០២០ [៥]*

## ៤.២ កត្តាជម្រុញដល់ការបាត់បង់ព្រៃកោងកាង

ប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី ប្រឈមកត្តាធំៗចំនួន៦ដូចគ្នា ដែលជំរុញឱ្យមានការបាត់បង់ព្រៃកោងកាង៖ ១) វារីវប្បកម្ម (ការចិញ្ចឹមបង្គា) ២) កសិកម្ម (កសិដ្ឋានអំបិល ការដាំដុះដំណាំស្រូវ និងចំការដូងប្រេង) ៣) នគរូបនីយកម្ម (ការពង្រីកទីក្រុង និងការតាំងទីលំនៅរបស់មនុស្ស) ៤) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ផែសមុទ្រ ផ្លូវថ្នល់ កំពង់ផែ និងហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងទេសចរណ៍) ៥) សកម្មភាពមនុស្សផ្សេងទៀត (ផលិតកម្មធ្យូង ការអភិវឌ្ឍឆ្នេរសមុទ្រដែលគ្មានការគ្រប់គ្រង ផលិតកម្មឈើ និងភាពក្រីក្រ) និង ៦) កត្តាធម្មជាតិ (ការប្រែប្រួលអាកាសធាតុ បាតុភូតអាកាសធាតុ និងការហូរច្រោះ) [១៤,១៥,១៧,១៨,១៩,២០,២១,២២,២៣,២៤,២៥]។

កត្តាទាំងប្រាំមួយនេះ គឺជាកត្តារួមចំណែកទូទៅដល់ការបាត់បង់ព្រៃកោងកាងនៅប្រទេសទាំងបី បើទោះបីកើតឡើងក្នុងចន្លោះពេលខុសៗគ្នា។ ករណីប្រទេសឥណ្ឌូនេស៊ី តាមការសិក្សាមួយចំនួនបានរកឃើញថា ការកាប់ឆ្ការព្រៃកោងកាងសម្រាប់ផលិតកម្មឈើ គឺជាកត្តាចំបងដែលជំរុញឱ្យមានការបាត់បង់ព្រៃកោងកាងនៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០ [២៣]។ ខណៈនៅប្រទេសថៃ យោងតាមអង្គការអាយយូស៊ីអិន (IUCN) ព្រៃកោងកាង៥៦ភាគរយត្រូវបានកាប់រានដើម្បីប្រកបមុខរបរវារីវប្បកម្មបង្គា និងកសិដ្ឋានអំបិលនៅចន្លោះឆ្នាំ១៩៦១-១៩៩៦ [១៧] ។

## ៥. ប្រភេទជម្លោះ និងការរំលោភបំពានលើសិទ្ធិកាន់កាប់ព្រៃកោងកាង

នៅប្រទេសកម្ពុជា ជម្លោះសិទ្ធិកាន់កាប់ព្រៃកោងកាងបានកើតឡើងភាគច្រើននៅលើដីសាធារណៈរបស់រដ្ឋ ដីក្នុងតំបន់ការពារធម្មជាតិ និងដីសហគមន៍នេសាទ។ ខេត្តកោះកុង និងកំពត ជាខេត្តដែលមានជម្លោះ និងការរំលោភបំពានញឹកញាប់ជាងគេ បន្ទាប់មកគឺខេត្តកែប និងខេត្តព្រះសីហនុ។ ដូចគ្នានឹងប្រទេសកម្ពុជាដែរ នៅប្រទេសថៃ ជម្លោះព្រៃកោងកាង តែងតែកើតឡើងនៅលើដីសាធារណៈរបស់រដ្ឋ តំបន់ការពារធម្មជាតិ ព្រៃបម្រុង និងដីសហគមន៍ ហើយជម្លោះទាំងនោះកើតឡើងភាគច្រើននៅខេត្តភូកេត។ ដោយឡែកនៅប្រទេស ឥណ្ឌូនេស៊ី ជម្លោះកាន់កាប់ព្រៃកោងកាងទាំងអស់ កើតឡើងនៅក្នុងតំបន់ការពារធម្មជាតិរបស់រដ្ឋ និងដីសាធារណៈ។ គួរកត់សម្គាល់ផងដែរថា ជម្លោះលើព្រៃកោងកាងក្នុងប្រទេសទាំងបីនេះ បានកើតឡើងជាទូទៅក្នុងទម្រង់ជា [១៤,១៥,១៧,១៨,១៩,២០,២១,២២,២៣,២៤,២៥]៖

១. ការកាប់ឆ្ការ ឬទន្ទ្រានព្រៃកោងកាងក្នុងតំបន់ការពារ ឬតំបន់ព្រៃសាធារណៈរបស់រដ្ឋ

២. ការចេញប័ណ្ណកម្មសិទ្ធិខុសច្បាប់លើព្រៃកោងកាងក្នុងតំបន់ការពារធម្មជាតិ ឬតំបន់ព្រៃបម្រុង

៣. ការទាមទារត្រួតគ្នាលើសិទ្ធិកាន់កាប់ព្រៃកោងកាង រវាងអ្នកវិនិយោគដែលមានអាជ្ញាប័ណ្ណ និងសហគមន៍ ។

## ៦. អភិបាលកិច្ចព្រៃកោងកាង

### ៦.១ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

ប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី មានវិធីសាស្ត្រក្នុងការគ្រប់គ្រងព្រៃកោងកាងប្រហាក់ប្រហែលគ្នា ប៉ុន្តែបានកំណត់គោលដៅអាទិភាពខុសៗគ្នា។ ប្រទេសកម្ពុជា ដែលមានគម្របព្រៃកោងកាងតិច មានគម្រោងការពារព្រៃកោងកាង ដើម្បីរក្សាប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរប្រកបដោយចីរភាព [២៦]។ ប្រទេសថៃធ្វើការការពារព្រៃកោងកាង ក្នុងគោលបំណងការពារធនធានតំបន់ឆ្នេរ ប៉ុន្តែផ្តល់អាទិភាពដល់កិច្ចការពារគ្រោះមហន្តរាយធម្មជាតិ និងការហូរច្រោះឆ្នេរ [២៧] ។ ប្រទេសឥណ្ឌូនេស៊ី ដែលមានផ្ទៃដីព្រៃកោងកាងធំជាងគេនៅក្នុងតំបន់ និងក្នុងពិភពលោក បានប្តេជ្ញាចិត្តក្នុងការការពារព្រៃកោងកាង ដើម្បីសម្រេចបាននូវអាងស្រូបកាបូន[1]នៅត្រឹមឆ្នាំ២០៣០ ដូចដែលបានកំណត់ក្នុងរបៀបវារៈនៃការប្រែប្រួលអាកាសធាតុពិភពលោក [២៨]។

ខណៈព្រៃកោងកាងត្រូវបានគេចាត់ទុកថា ជាបញ្ហាអន្តរវិស័យ ព្រោះវាជាធនធានដែលស្ថិតនៅទាំងលើដីនិងក្នុងសមុទ្រ អភិបាលកិច្ចព្រៃកោងកាង ត្រូវជាប់ពាក់ព័ន្ធនឹងច្បាប់គតិយុត្ត និងគោលនយោបាយជាច្រើន។ ក្រៅពីពាក់ព័ន្ធនឹងច្បាប់ស្តីពីជលផល និងព្រៃឈើ ក៏ពាក់ព័ន្ធនឹងច្បាប់ផ្សេងៗទៀត ដូចជា ច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ តំបន់ការពារធម្មជាតិនិងឧទ្យានជាតិ ការគ្រប់គ្រងធនធានសមុទ្រ និងឆ្នេរសមុទ្រ និងសិទ្ធិកាន់កាប់ដីធ្លី (មើលតារាងទី ២)។

[1] អាងស្រូបកាបូនសំដៅលើដំណើរការបែបធម្មជាតិឬសិប្បនិម្មិតក្នុងការដកឧស្ម័នផ្ទះកញ្ចក់ឬកាបូនចេញពីបរិយាកាស។

***តារាងទី ២៖ ច្បាប់ និងគោលនយោបាយមានស្រាប់ ដែលកំណត់អភិបាលកិច្ចព្រៃកោងកាង ក្នុងប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី***

| ថៃ | កម្ពុជា | ឥណ្ឌូនេស៊ី |
|---|---|---|
| ▪ ច្បាប់ព្រៃឈើ ១៩៤១<br>▪ វិសោធនកម្មច្បាប់ដីធ្លី ១៩៥៤<br>▪ ច្បាប់ឧទ្យានជាតិ ១៩៦១<br>▪ ច្បាប់រក្សាព្រៃឈើជាតិ ១៩៦៤<br>▪ ព្រះរាជប្រកាសព្រះមហាក្សត្ររាមាទី៩ ១៩៩១<br>▪ ច្បាប់រក្សា និងការពារសត្វព្រៃ ១៩៩២<br>▪ ច្បាប់ ស្តីពីចម្ការព្រៃពាណិជ្ជកម្ម ១៩៩២<br>▪ ច្បាប់វិមជ្ឈការ ១៩៩៩<br>▪ ច្បាប់គ្រប់គ្រង ធនធានតំបន់ឆ្នេរ និងសមុទ្រ ២០១៥<br>▪ ច្បាប់ ស្តីពីការលើកកម្ពស់ និងអភិរក្សគុណភាពបរិស្ថានជាតិ ១៩៩២/ ២០១៨<br>▪ ច្បាប់ព្រៃឈើសហគមន៍ ពុទ្ធស័ករាជ ២០១៩/ ២៥៦២ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>▪ ច្បាប់ស្តីពីជលផល ២០០៦ និងសេចក្តីព្រាងច្បាប់ថ្មី<br>▪ ច្បាប់ព្រៃឈើ ២០០២ និងសេចក្តីព្រាងច្បាប់ថ្មី<br>▪ អនុក្រឹត្យលេខ៧៩ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ២០០៣<br>▪ អនុក្រឹត្យលេខ២៥ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ២០០៧<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>▪ អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច ២០០៥<br>▪ អនុក្រិត្យលេខ១៤៨ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ២០០៥<br>ក្រសួងបរិស្ថាន<br>▪ ក្រមបរិស្ថាន និងធនធានធម្មជាតិ ២០២៣<br>▪ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ១៩៩៦<br>▪ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ២០០៨ និងសេចក្តីព្រាងច្បាប់ថ្មី<br>▪ អនុក្រិត្យស្តីពីការគ្រប់គ្រងការបំពុលទឹក១៩៩៩<br>▪ អនុក្រិត្យស្តីពីការគ្រប់គ្រងសំណល់រឹង១៩៩៩<br>▪ អនុក្រិត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១៩៩៩<br>▪ យុទ្ធសាស្ត្រគ្រប់គ្រងច្រាំងសមុទ្ររបស់កម្ពុជា ២០០៦<br>▪ គោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>▪ ច្បាប់ភូមិបាល ២០០១ និងសេចក្តីព្រាងច្បាប់ថ្មី<br>▪ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ២០០៣ | ▪ ច្បាប់កសិកម្ម ១៩៦០<br>▪ ច្បាប់ ស្តីពីការការពារធនធានធម្មជាតិ ជីវសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ី ១៩៩០<br>▪ ច្បាប់លេខ៤១ស្តីពីព្រៃឈើ ១៩៩៩<br>▪ ច្បាប់ ស្តីពីការការពារ និងការគ្រប់គ្រងបរិស្ថាន ២០០៩<br>▪ ច្បាប់ ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ និងកោះតូចៗ ២០០៧/២០១៤ និង<br>▪ ច្បាប់ស្តីពី រដ្ឋាភិបាលតំបន់ ២០១៤ |

| | | |
|---|---|---|
| | ក្រសួងមហាផ្ទៃ<br>▪ អនុក្រឹត្យ១៨២ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង<br>▪ អនុក្រឹត្យ១៨៤ស្តីពីមុខងារ និងរចនាសម្ព័ន្ធស្រុក | |
| | ក្រសួងធនធានទឹក និងឧតុនិយម<br>▪ ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក២០០៧ | |
| | គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ<br>▪ ព្រះរាជក្រិត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ២០១២<br>▪ អនុក្រិត្យលេខ១៧១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ២០១២ | |
| | គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ<br>▪ សេចក្តីសម្រេចលេខ១២៧ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ២០១៦ | |
| ▪ គោលនយោបាយ ស្តីពីការកំណត់ និងបែងចែកតំបន់ព្រៃកោងកាង ១៩៨៧<br>▪ គោលនយោបាយស្តារព្រៃកោងកាង ១៩៩១<br>▪ សេចក្តីសម្រេចរដ្ឋាភិបាល ១៩៩៩<br>▪ ផែនការជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ២០០៧-២០២១ | រាជរដ្ឋាភិបាលកម្ពុជា<br>▪ សារាចរណែនាំលេខ០១ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ២០១២<br>▪ សារាចរណែនាំលេខ០៥ស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ២០១៦<br>▪ សេចក្តីសម្រេច លេខ៤៥ស្តីពីបទប្បញ្ញត្តិក្នុងការបង្កើតការការពារ និងគ្រប់គ្រងធនធានសមុទ្រ២០១៣ | ▪ ក្រឹត្យប្រធានាធិបតីលេខ៣២ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ១៩៩០<br>▪ ក្រឹត្យប្រធានាធិបតី ស្តីពីការការពារព្រៃឈើ២០០៤<br>▪ ក្រឹត្យប្រធានាធិបតី ស្តីពីយុទ្ធសាស្រ្តជាតិ សម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងឆ្នាំ ២០១២<br>▪ ក្រឹត្យប្រធានាធិបតី ស្តីពីក្រុមសម្របសម្រួល យុទ្ធសាស្រ្តសម្រាប់ការគ្រប់គ្រងដីសើម ២០២០ |

នៅប្រទេសកម្ពុជា ព្រៃកោងកាង គឺជាផ្នែកមួយនៃធនធានជលផល ដូច្នេះច្បាប់ស្តីពី ជលផល ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៦ ផ្តល់ជាក្របខ័ណ្ឌនានាក្នុងការគ្រប់គ្រងព្រៃកោងកាង។ នៅប្រទេសថៃ ព្រៃកោងកាងត្រូវបានចាត់ថ្នាក់ជាព្រៃឈើ ដូច្នេះហើយទើបច្បាប់នានាពាក់ព័ន្ធនឹងវិស័យព្រៃឈើ ដូចជាច្បាប់ព្រៃឈើ ពុទ្ធសករាជ ២៤៨៤ ដែលត្រូវបាន

អនុម័តនៅឆ្នាំ១៩៤១ ច្បាប់ឧទ្យានជាតិពុទ្ធសករាជ២៥០៤ ដែលត្រូវបានអនុម័តនៅឆ្នាំ១៩៦១ និងច្បាប់គ្រប់គ្រងធនធានតំបន់ឆ្នេរនិងសមុទ្រពុទ្ធសករាជ២៥៥៨ ដែលត្រូវបានអនុម័តនៅឆ្នាំ២០១៥ ត្រូវបានអនុវត្តចំពោះព្រៃកោងកាង [២៩]។ នៅប្រទេសឥណ្ឌូនេស៊ី ការគ្រប់គ្រងព្រៃកោងកាង រួមបញ្ចូលផ្នែកធំៗពីរគឺ វិស័យព្រៃឈើ និងវិស័យជលផល និងឆ្នេរសមុទ្រ។ ដូច្នេះ បទប្បញ្ញត្តិនានា ដែលជាមូលដ្ឋានសម្រាប់ការការពារព្រៃកោងកាង រួមមានច្បាប់កសិកម្មជាមូលដ្ឋានអនុម័តក្នុងឆ្នាំ១៩៦០ ច្បាប់លេខ៥អនុម័តក្នុងឆ្នាំ១៩៩០ ស្តីពីការការពារធនធានធម្មជាតិជីវសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ី និងបទប្បញ្ញត្តិនៃក្រឹត្យប្រធានាធិបតីលេខ៣២ អនុម័តក្នុងឆ្នាំ១៩៩០ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ព្រមជាមួយច្បាប់លេខ៤១ ស្តីពីព្រៃឈើដែលបានអនុម័តក្នុងឆ្នាំ១៩៩៩ [២៤,៣០]។

នៅកម្ពុជា ក្នុងរយៈពេលប្រាំពីរឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការធ្វើវិសោធនកម្មច្បាប់មួយចំនួនដូចជា ច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ច្បាប់ស្តីពីជលផលឆ្នាំ២០០៦ និងច្បាប់តំបន់ការពារធម្មជាតិឆ្នាំ២០០៨ ដើម្បីលើកកម្ពស់កិច្ចការពារធនធានធម្មជាតិ ជាពិសេសព្រៃកោងកាង និងសិទ្ធិកាន់កាប់ដី។ ប្រអប់ទី១ រៀបរាប់ពីដំណើរការវិសោធនកម្មច្បាប់នាពេលបច្ចុប្បន្នពាក់ព័ន្ធនឹងព្រៃកោងកាងនៅកម្ពុជា។

ទាក់ទងនឹងអភិបាលកិច្ចព្រៃកោងកាងនៅប្រទេសកម្ពុជា យ៉ាងហោចណាស់មានច្បាប់ចំនួន៧ (ច្បាប់៤កំពុងត្រូវគេធ្វើវិសោធនកម្ម) ក្រមបរិស្ថាននិងធនធានធម្មជាតិចំនួន១ ព្រះរាជក្រឹត្យចំនួន១ និងអនុក្រឹត្យចំនួន១០ ខណៈនៅប្រទេសថៃមានច្បាប់ចំនួន១០ និងព្រះរាជប្រកាសព្រះមហាក្សត្រចំនួន១ ហើយនៅប្រទេសឥណ្ឌូនេស៊ី យ៉ាងហោចណាស់មានច្បាប់ចំនួន៦ និងក្រឹត្យប្រធានាធិបតីចំនួន៤ (សូមមើលតារាងទី៣)។

**ប្រអប់ទី១៖ បច្ចុប្បន្នភាពនៃដំណើរការវិសោធនកម្មច្បាប់ ពាក់ព័ន្ធទៅនឹងព្រៃកោងកាងនៅកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើវិសោធនកម្មច្បាប់ ក្នុងរយៈពេលប្រាំពីរឆ្នាំចុងក្រោយនេះ ទាក់ទងនឹងធនធានធម្មជាតិ ជាពិសេសព្រៃកោងកាង។ យោងតាមសេចក្តីជូនដំណឹងស្តីពីសមិទ្ធផលនៅក្នុងសម័យប្រជុំពេញអង្គនៃទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមរយៈលិខិតលេខ ១៣០៣ ស.ជ.ណ.ស.រ បានឲ្យដឹងថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) កំពុងដឹកនាំរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីជលផល ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ច្បាប់ទាំងបីដែលកំពុងត្រូវបានកែប្រែចុងក្រោយនេះ មានគោលការណ៍ធានានូវការអភិវឌ្ឍប្រកបដោយចីរភាព អភិបាលកិច្ចល្អ តម្លាភាព និងការចូលរួម ដើម្បីបង្កើតវិធីសាស្ត្របង្ការទុកជាមុន និងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ។ គោលការណ៍ទាំងនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តក្នុងតំបន់ និងអន្តរជាតិចំពោះការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព។

នៅខែវិច្ឆិកា ឆ្នាំ២០១៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាប់ផ្តើមធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល ដោយបានផ្លាស់ប្តូរមាត្រាទី ៦,៤១,៤២,៤៣ និង៩៥។ វិសោធនកម្មនេះបាននាំមកនូវការផ្លាស់ប្តូរសំខាន់ៗចំនួនបីដល់វិស័យជលផលនៅក្នុងពង្រាងច្បាប់។ ការផ្លាស់ប្តូរទីមួយគឺថា ទីស្នាក់ការដែនជលផលត្រូវបានច្របាច់បញ្ចូលទៅក្នុងមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទខេត្ត តាមមាត្រានៃច្បាប់ដែលបានធ្វើវិសោធនកម្មថ្មីនេះ។ ការផ្លាស់ប្តូរទីពីរ គឺចំណាត់ថ្នាក់ឧបករណ៍សម្រាប់សកម្មភាពនេសាទបែបពាណិជ្ជកម្ម ជាពិសេសប្រតិបត្តិការខ្នាតមធ្យម និងខ្នាតធំ ក៏ត្រូវបានកែសម្រួលដែរ។ ការផ្លាស់ប្តូរទីបី គឺថា ផែនការថ្មីៗសម្រាប់បង្ក្រាបបទល្មើស និងការផាកពិន័យ រួមបញ្ចូលទាំងបទល្មើសទាក់ទងនឹងព្រៃកោងកាងផងនោះ បានត្រូវដាក់បញ្ចូល។

សេចក្តីព្រាងច្បាប់ទាំងបី ត្រូវបានពិនិត្យយ៉ាងម៉ត់ចត់ដោយក្រុមអ្នកច្បាប់រួមមាន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភា ពិនិត្យសម្រេចនៅឆ្នាំ២០២៤។ តួនាទីជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដូចជាព្រៃឈើ ព្រៃកោងកាង ធនធានជលផល និងតំបន់ការពារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន នឹងត្រូវកំណត់ដោយអនុក្រឹត្យ ដោយផ្អែកលើច្បាប់ទាំងបីនេះ ក្រោយពីបានធ្វើវិសោធនកម្ម។ លើសពីនេះទៅទៀត ច្បាប់ទាំងបីដែលនឹងត្រូវធ្វើវិសោធនកម្ម នឹងធានាបាននូវការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានឱ្យបានត្រឹមត្រូវ តាមរយៈការផ្ទេរភារកិច្ចជាក់លាក់ទៅឱ្យរដ្ឋបាលគ្រប់គ្រងថ្នាក់ក្រោមជាតិ។

ក្រៅពីសេចក្តីព្រាងច្បាប់ទាំងបីខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏កំពុងរៀបចំសេចក្តីព្រាងច្បាប់ភូមិបាលថ្មីផងដែរ។ មកដល់ពេលនេះ សេចក្តីព្រាងច្បាប់ភូមិបាលថ្មី កំពុងស្ថិតក្នុងដំណើរការពិគ្រោះយោបល់សាធារណៈ ដើម្បីប្រមូលធាតុចូលពីបណ្តាញអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្នុងការពិចារណានៅដើមឆ្នាំ ២០២៤។

ច្បាប់មួយទៀតដែលពាក់ព័ន្ធនឹងព្រៃកោងកាងដែរនោះ គឺក្រមបរិស្ថាន និងធនធានធម្មជាតិ។ នៅក្នុងខែមិថុនា ឆ្នាំ ២០២៣ ក្រសួងបរិស្ថានក៏បានដាក់ឱ្យប្រើប្រាស់នូវក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលមាន១២គន្ថី និង៨៦៥ មាត្រា។ ការគ្រប់គ្រងព្រៃកោងកាងមានចែងក្នុងគន្ថីទី៤ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិ តំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

*តារាងទី ៣: ចំនួនច្បាប់ បទបញ្ញត្តិ និងគោលនយោបាយ ស្ថាប័នអន្តរក្រសួង និងក្រសួងពាក់ព័ន្ធក្នុងការគ្រប់គ្រងព្រៃកោងកាងនៅទូទាំងប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី*

| | ច្បាប់/បទបញ្ញត្តិ/គោលនយោបាយ | ស្ថាប័នអន្តរក្រសួង | ក្រសួងគាំទ្រ |
|---|---|---|---|
| **កម្ពុជា** | ▪ ច្បាប់៧ (ច្បាប់៤កំពុងត្រូវគេធ្វើវិសោធនកម្ម)<br>▪ ព្រះរាជក្រឹត្យ១<br>▪ ក្រម១<br>▪ អនុក្រឹត្យ១០<br>▪ សារាចរ/សេចក្តីសម្រេច៤ របស់គណៈរដ្ឋមន្ត្រី/បទបញ្ញត្តិ<br>▪ គោលនយោបាយ និងប្រភេទឯកសារផ្សេងទៀត | ▪ គណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា២០១២<br>▪ គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិឆ្នាំ២០១៦ | ▪ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>▪ ក្រសួងបរិស្ថាន<br>▪ ក្រសួងរៀបចំដែនដី នគរូបនីយ កម្ម និងសំណង់<br>▪ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>▪ ក្រសួងមហាផ្ទៃ<br>▪ ក្រសួងធនធានទឹក និងឧតុនិយម<br>▪ ក្រសួងទេសចរណ៍ |
| **ថៃ** | ▪ ច្បាប់១០<br>▪ ប្រកាសព្រះមហាក្សត្រ១<br>▪ គោលនយោបាយផ្សេងៗ | ▪ គណៈកម្មាធិការជាតិ ស្តីពីគោលនយោបាយ និង ផែនការ គ្រប់គ្រងធនធានតំបន់ឆ្នេរ និងសមុទ្រ | ▪ ក្រសួង ធនធានធម្មជាតិនិង បរិស្ថាន<br>▪ កងទ័ពជើងទឹកថៃ<br>▪ ក្រសួងមហាផ្ទៃ |
| **ឥណ្ឌូនេស៊ី** | ▪ ច្បាប់៦<br>▪ ក្រឹត្យប្រធានាធិបតី៤<br>▪ គោលនយោបាយផ្សេងៗ | ▪ ក្រុមសម្របសម្រួល យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងដីសើម | ▪ ក្រសួងបរិស្ថាន និងព្រៃឈើ<br>▪ ក្រសួង កិច្ចការសមុទ្រ និងនេសាទ<br>▪ ក្រសួង កិច្ចការកសិកម្ម និងផែនការទីតាំងក្នុងលំហ/ភ្នាក់ងារដីជាតិ<br>▪ ក្រសួងផែនការអភិវឌ្ឍន៍ជាតិ |

ជាធម្មតា នៅក្នុងប្រទេសទាំងបីនេះ ព្រៃកោងកាងត្រូវបានគ្រប់គ្រងដោយអន្តរក្រសួង ដោយសារភាពស្មុគស្មាញ និងទំនាក់ទំនងនៃប្រព័ន្ធអេកូឡូស៊ីរបស់វា។ នៅកម្ពុជា ព្រៃកោងកាងត្រូវបានរកឃើញនៅក្នុងដែនសមត្ថកិច្ចវិស័យចំនួន៦ដូចជា៖១) តំបន់ការពារធម្មជាតិ ២)សហគមន៍ការពារធម្មជាតិ ៣) សហគមន៍នេសាទ ៤) ដែនសម្បទានសេដ្ឋកិច្ច ៥) តំបន់សម្បទានសេដ្ឋកិច្ចពិសេស និង៦) កម្មសិទ្ធិដីឯកជន។ ដូច្នេះ យ៉ាងហោចណាស់ក៏មានក្រសួងចំនួន៧ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃកោងកាងនៅកម្ពុជា ខណៈនៅឥណ្ឌូនេស៊ី មានក្រសួងចំនួន៤ ពាក់ព័ន្ធនឹងអភិបាលកិច្ចព្រៃកោងកាង។ ដោយឡែកនៅប្រទេសថៃ ព្រៃកោងកាងភាគច្រើនស្ថិតនៅដែនសមត្ថកិច្ចរបស់ក្រសួងធនធានធម្មជាតិ និងបរិស្ថាន បើ

ទោះបីជាក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានពីរផ្សេងគ្នាក៏ដោយ។ មានតែព្រៃកោងកាងនៅមូលដ្ឋានជើងទឹកប៉ុណ្ណោះ ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ័ពជើងទឹកភូមិន្ទថៃ។

ភាពដូចគ្នារវាងប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី គឺថារដ្ឋាភិបាលបានបង្កើតស្ថាប័នអន្តរក្រសួងដើម្បីជួយសម្រប សម្រួលការងារគ្រប់គ្រងព្រៃកោងកាង [៣១,៣២,៣៣]។ តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នអន្តរក្រសួង និង បណ្តាក្រសួងពាក់ព័ន្ធនានា មានបង្ហាញនៅក្នុងតារាងឧបសម្ព័ន្ធ។

បើនិយាយដល់សិទ្ធិកាន់កាប់ព្រៃកោងកាង នៅក្នុងប្រទេសទាំងបី ព្រៃកោងកាង ត្រូវបានគេចាត់ទុកជាទ្រព្យ សម្បត្តិសាធារណៈរបស់រដ្ឋ។ ដូច្នេះ ការតាំងទីលំនៅរបស់មនុស្ស និងការប្រើប្រាស់ព្រៃកោងកាងជា លក្ខណៈឯក ជន នៅក្នុងតំបន់ព្រៃកោងកាងរបស់រដ្ឋ រួមបញ្ចូលទាំងតំបន់ការពារធម្មជាតិ ត្រូវបានហាមឃាត់។ ទោះបីជាយ៉ាងណាក៏ ដោយ នៅមានករណីលើកលែងខ្លះៗដូចជា នៅពេលដែល "ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បានបាត់បង់ផល ប្រយោជន៍សាធារណៈរបស់ខ្លួន ទ្រព្យសម្បត្តិទាំងនោះ អាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ" ដោយ ផ្អែកលើច្បាប់ភូមិបាលឆ្នាំ២០០១ នៃប្រទេសកម្ពុជា [៣៤] ឬនៅពេលដែលមានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ដែលចេញ ដោយក្រសួងធនធានធម្មជាតិនិងបរិស្ថាន ដោយផ្អែកលើច្បាប់រក្សាព្រៃឈើជាតិឆ្នាំ១៩៦៤ នៃប្រទេសថៃ [២៩] ឬនៅ ពេលដែលអាជ្ញាប័ណ្ណទីតាំង ឬអាជ្ញាប័ណ្ណគ្រប់គ្រងត្រូវបានអនុម័ត ដោយផ្អែកលើច្បាប់ស្តីពីវិសោធនកម្មលេខ២៧នៃ ច្បាប់ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរនិងកោះតូចៗឆ្នាំ២០១៤ របស់ប្រទេសឥណ្ឌូនេស៊ី [៣៥]។

ច្បាប់នៃប្រទេសទាំងបី ក៏បានទទួលស្គាល់សិទ្ធិរបស់សហគមន៍លើព្រៃកោងកាងផងដែរ (សូមមើលតារាងទី៤)។ ប៉ុន្តែកម្រិតនៃការផ្ទេរអំណាចក្នុងការគ្រប់គ្រងព្រៃកោងកាងដល់សហគមន៍ នៅមានលក្ខណៈប្រែប្រួលទៅតាមប្រទេសនី មួយៗ។ ប្រទេសថៃ ហាក់ដូចជាបានបង្ហាញការប្តេជ្ញាចិត្តខ្ពស់ចំពោះសិទ្ធិកាន់កាប់របស់សហគមន៍ តាមរយៈការខិតខំ ប្រឹងប្រែងរបស់ខ្លួនក្នុងការអនុម័តច្បាប់ព្រៃឈើសហគមន៍ ពុទ្ធស័ករាជ២៥៦២ ក្នុងឆ្នាំ២០១៩។ ដោយឡែកនៅកម្ពុជា និងឥណ្ឌូនេស៊ី ទោះបីជាមិនទាន់មានច្បាប់ដាច់ដោយឡែកពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់របស់សហគមន៍ក៏ដោយ កម្ពុជានិង ឥណ្ឌូនេស៊ី បានបញ្ចូលសិទ្ធិសហគមន៍ទៅក្នុងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់រៀងៗខ្លួន ដោយសម្រាប់ប្រទេសកម្ពុជា មាន ដូចជាច្បាប់ស្តីពីជលផលឆ្នាំ២០០៦ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើឆ្នាំ២០០៣ អនុក្រឹត្យស្តីពីការ គ្រប់គ្រងសហគមន៍នេសាទឆ្នាំ២០០៧ ច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ និង សម្រាប់ប្រទេសឥណ្ឌូនេស៊ី មានដូចជាច្បាប់លេខ១ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ និងកោះតូចៗឆ្នាំ២០១៤ ច្បាប់លេខ៣២ស្តីពី ការការពារ និងគ្រប់គ្រងបរិស្ថាន២០០៩ និងក្រឹត្យប្រធានាធិបតីលេខ៧៣ ឆ្នាំ២០១២។ វាជាការចាំបាច់ដែលគួរមានការ វិភាគផ្អែកច្បាប់ ដើម្បីពន្យល់ពីកម្រិតនៃការការពារដោយច្បាប់ទៅលើសិទ្ធិសហគមន៍នៅក្នុងប្រទេសទាំងបី ។

***តារាងទី៤៖ ច្បាប់មានស្រាប់ពាក់ព័ន្ធនឹងសិទ្ធិសហគមន៍ ចំពោះព្រៃកោងកាងនៅកម្ពុជា ថៃ និងឥណ្ឌូនេស៊ី***

| កម្ពុជា | ថៃ | ឥណ្ឌូនេស៊ី |
|---|---|---|
| ▪ ច្បាប់ស្តីពីជលផលឆ្នាំ២០០៦<br>▪ អនុក្រឹត្យលេខ៧៩ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ២០០៣<br>▪ អនុក្រឹត្យលេខ២៥ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទឆ្នាំ ២០០៧<br>▪ ច្បាប់ភូមិបាលឆ្នាំ ២០០១<br>▪ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ | ▪ ច្បាប់សហគមន៍ព្រៃឈើ ពុទ្ធសករាជ ២៥៦២ | ▪ ច្បាប់លេខ៣២ ស្តីពីការការពារ និងគ្រប់គ្រងបរិស្ថាន ឆ្នាំ២០០៩<br>▪ ច្បាប់លេខ១ ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ និងកោះតូច ឆ្នាំ២០១៤<br>▪ ក្រឹត្យប្រធានាធិបតី លេខ៧៣ ស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រង ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ឆ្នាំ ២០១២ |

## ៦.២ បញ្ហាប្រឈមផ្នែកអភិបាលកិច្ច

ដូចបណ្តាប្រទេសដទៃទៀតលើសកលលោកដែរ អភិបាលកិច្ចព្រៃកោងកាងនៅក្នុងប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី នៅតែមានភាពស្មុគស្មាញ។ អភិបាលកិច្ចព្រៃកោងកាង មានភាពស្មុគ្រស្មាញ ព្រោះមានការពាក់ព័ន្ធនឹងបណ្តាស្ថាប័នអន្តរវិស័យ ដែលរួមមានវិស័យព្រៃឈើ ជលផល ដែនដី តំបន់ឆ្នេរ ធនធានសមុទ្រ និងតំបន់ការពារធម្មជាតិ ដែលសុទ្ធតែជាវិស័យអាទិភាព និងមានទិសដៅផ្សេងៗគ្នា [៣០, ៣១] ។

ទោះបីជាប្រទេសថៃ បានព្យាយាមដាក់វិសាលភាពព្រៃកោងកាងភាគច្រើនឱ្យនៅក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងធនធានធម្មជាតិនិងបរិស្ថាន ក៏អភិបាលកិច្ចនិងការគ្រប់គ្រងព្រៃកោងកាងនៅតែមានភាពស្មុគស្មាញ ដោយសារតែព្រៃកោងកាងស្ថិតនៅតំបន់មានសក្តានុពលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច (ឧទា.ការសាងសង់កំពង់ផែពាណិជ្ជកម្ម ការចិញ្ចឹមបង្គា កសិកម្ម អចលនទ្រព្យ រមណីយដ្ឋានផ្សេងៗ។ល។) ដែលត្រូវពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់វិស័យជាច្រើន។ ដើម្បីស្តារព្រៃកោងកាងឡើងវិញ គម្រោងអាទិភាពអភិវឌ្ឍន៍សេដ្ឋកិច្ចទាំងអស់ គួរត្រូវគេសិក្សាឱ្យបានហ្មត់ចត់ ដើម្បីប្រៀបធៀបផលប្រយោជន៍របស់គម្រោងទៅនឹងតម្លៃអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គមរបស់ព្រៃកោងកាង [៣៦] ។

រដ្ឋាភិបាលនៃប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី ក៏បានខិតខំប្រឹងប្រែងដោះស្រាយបញ្ហាទាំងនេះ តាមរយៈការបង្កើតស្ថាប័នពហុវិស័យ ក្នុងការសម្របសម្រួលការងារអន្តរវិស័យផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តជាក់ស្តែងរបស់ស្ថាប័នទាំងនេះ នៅមានកម្រិតដោយសារបញ្ហាថវិកា និងកង្វះយន្តការក្នុងការបំពេញការងាររួមគ្នាលើពហុវិស័យ និងគ្រប់ជាន់ថ្នាក់នៃរដ្ឋាភិបាល [៣០,៣៧,៣៨]។

ប្រសិទ្ធភាពនៃការគ្រប់គ្រងព្រៃកោងកាង ក៏ទាមទារឱ្យមានការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តត្រឹមត្រូវ និងមានប្រសិទ្ធភាពផងដែរ។ នេះមានន័យថា ច្បាប់ និងគោលនយោបាយ គួរតែត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ស្របតាមគោលការណ៍សិទ្ធិមនុស្ស ដោយពិចារណាទៅលើស្ថានភាពជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ស្ត្រី និងក្រុមជនងាយរងគ្រោះ ជនក្រីក្រ និង/ឬក្រុមដែលមានសម្លេងភាគតិចក្នុងសង្គម ហើយក៏គួរតែបញ្ចូលនូវគោលការណ៍ចីរភាពបរិស្ថានផងដែរ [៣៩] ។

ភាពមិនច្បាស់លាស់ក្នុងសិទ្ធិកាន់កាប់ព្រៃកោងកាង គឺជាកត្តាជំរុញមួយទៀតដែលបង្កជម្លោះ និងការបណ្តេញចេញដោយបង្ខំលើប្រជាពលរដ្ឋនៅក្នុងប្រទេសទាំងបី។ ទោះបីជាប្រទេសទាំងបីមានបទបញ្ញត្តិស្តីពីសិទ្ធិកាន់កាប់ដីធ្លីក៏ដោយ ក៏ជម្លោះលើព្រៃកោងកាងក្នុងប្រទេសទាំងបី នៅតែកើតមានជុំវិញបញ្ហាដែលភាគីពាក់ព័ន្ធទាមទារសិទ្ធិកាន់កាប់ព្រៃកោងកាងនៅក្នុងតំបន់តែមួយ ។ កត្តានេះ នាំឱ្យមានភាពតានតឹងកាន់តែច្រើន ដែលឆ្លុះបញ្ចាំងជាចម្បងនូវបញ្ហាភាពមិនច្បាស់លាស់ក្នុងសិទ្ធិកាន់កាប់ព្រៃកោងកាងក្នុងប្រទេសទាំងបី។ ដើម្បីដោះស្រាយបញ្ហានេះ គេចាំបាច់ត្រូវធ្វើការពង្រឹងសិទ្ធិកាន់កាប់ព្រៃកោងកាង តាមរយៈការពិនិត្យមើល និងការកំណត់ឡើងវិញនូវច្បាប់ និងបទបញ្ញត្តិដែលមានស្រាប់ ដើម្បីបន្ស៊ីគ្នាទៅនឹងកិច្ចការពារព្រៃកោងកាង [៤០] ។

បន្ថែមពីលើនេះ មានការទទួលស្គាល់កាន់តែច្រើនថា កិច្ចខិតខំប្រឹងប្រែងការពារព្រៃកោងកាង ដែលដឹកនាំដោយរដ្ឋាភិបាលតែឯង គឺមិនមានប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការការពារព្រៃកោងកាងឡើយ ដោយសារកត្តាមួយចំនួនដូចជា កង្វះខាតផ្នែកបុគ្គលិក សមត្ថភាពនៃនាយកដ្ឋានទទួលខុសត្រូវនៅមានកម្រិត និងថវិកាមិនគ្រប់គ្រាន់ [៤១]។ ដូច្នេះ និន្នាការអភិបាលកិច្ចព្រៃកោងកាង ដោយផ្តល់សិទ្ធិអំណាចដល់សហគមន៍ ឬការគ្រប់គ្រងរួមគ្នារវាងសហគមន៍និងរដ្ឋាភិបាល បានក្លាយជាវិធីសាស្រ្តគ្រប់គ្រងពេញនិយមនៅក្នុងប្រទេសទាំងបី។

ការបញ្ចូលសិទ្ធិកាន់កាប់សហគមន៍ទៅក្នុងច្បាប់ និងបទបញ្ញត្តិដែលមានស្រាប់ គឺបញ្ជាក់ពីការទទួលស្គាល់របស់រដ្ឋាភិបាលទៅលើសិទ្ធិសហគមន៍មួយកម្រិតហើយ។ ប៉ុន្តែចំនុចសំខាន់មួយទៀត គឺសហគមន៍គួរទទួលបានយុត្តិធម៌ និងដំណោះស្រាយនៅពេលមានបញ្ហាជម្លោះ។ សហគមន៍ខ្លួនឯងគួរតែយល់ដឹងអំពីសិទ្ធិពាក់ព័ន្ធនឹងធនធានធម្មជាតិ និងមធ្យោបាយសម្រាប់ការដោះស្រាយជម្លោះ ឬការស្នើសុំទូទាត់សំណង ។ សហគមន៍គួរតែអាចស្វែងរក និងទទួលបានការគាំពារពេលមានបណ្តឹងតវ៉ា និងទទួលបានដំណោះស្រាយចំពោះជម្លោះនានារបស់ពួកគេ [៣៩] ។

របកគំហើញពីការសិក្សាកន្លងមកនៅប្រទេសទាំងបីបានបង្ហាញថា កត្តាធម្មជាតិ ដូចជាការកើនឡើងនៃនីវ៉ូទឹកសមុទ្រ និងការហូរច្រោះកំពុងក្លាយជាកត្តាជំរុញដ៏ធ្ងន់ធ្ងរចំពោះការបាត់បង់ព្រៃកោងកាងនៅក្នុងតំបន់។ យុទ្ធសាស្រ្តនានាអាចនឹងត្រូវបានបង្កើតឡើង ដើម្បីកសាងភាពធន់ព្រៃកោងកាង ឆ្លើយតបទៅនឹងកត្តាធម្មជាតិទាំងនោះ តាមរយៈការអនុវត្តកម្មវិធីស្តារ និងធ្វើឱ្យប្រសើរឡើងវិញនូវព្រៃកោងកាងនៅតំបន់ដែលសឹករិចរិល [៤២]។ ប្រទេសឥណ្ឌូនេស៊ី

និងថៃ មានប្រវត្តិដ៏យូរលង់ក្នុងការអនុវត្តកម្មវិធីស្តារព្រៃកោងកាង ដែលអាចផ្តល់ជាបទពិសោធន៍ល្អៗសម្រាប់ប្រទេសកម្ពុជា យកមកពិចារណា។

ការស្តារព្រៃកោងកាងឡើងវិញអាចទទួលបរាជ័យ ប្រសិនបើគេមិនអនុវត្តកម្មវិធីឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ដូចជាមិនគួរដាំព្រៃកោងកាងតែមួយប្រភេទ ឬកង្វះការថែទាំ។ ប្រអប់ទី២ បង្ហាញពីបទពិសោធន៍ល្អៗពីការចូលរួមចំណែកនៃការស្តារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងដោយផ្អែកលើសហគមន៍នៅប្រទេសថៃ ក្នុងការលើកកម្ពស់អត្រានៅរស់របស់ព្រៃកោងកាង។

**ប្រអប់ទី២៖ ករណីសិក្សាអំពី ការស្តារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងដោយផ្អែកលើសហគមន៍ នៅភូមិទុងយោ ខេត្តក្របី ប្រទេសថៃ**

ការស្តារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងដោយផ្អែកលើសហគមន៍ (CBEMR) ត្រូវបានអនុវត្តនៅភូមិទុងយោ ខេត្តក្របី នៅភាគខាងត្បូងប្រទេសថៃតាំងពីឆ្នាំ២០១៧ តាមរយៈគម្រោងសកម្មភាពព្រៃកោងកាង (MAP)។ នៅដើមទស្សវត្សរ៍ឆ្នាំ ១៩៩០ ព្រៃកោងកាងនៅក្នុងភូមិទុងយោ ត្រូវបានកាប់រានដើម្បីធ្វើវារីវប្បកម្មបង្គា។ តាមរយៈកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញដោយប្រើប្រាស់វិធីសាស្ត្រ CBEMR នៅឆ្នាំ២០១៧ ភូមិទុងយោក៏ប្រែក្លាយជាភូមិបៃតងឡើងវិញក្នុងរយៈពេលតែ២ឬ៣ឆ្នាំ ដោយមានការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធ។ ក្រោយអនុវត្តវិធីសាស្ត្រនេះ គេបានរកឃើញថា នៅភូមិទុងយោ ព្រៃកោងកាងចំនួន១២ប្រភេទ ដោយរួមទាំងត្រីផងដែរ ចាប់ផ្តើមកកើត។ ការស្តារព្រៃកោងកាងឡើងវិញនៅភូមិទុងយោ មិនតម្រូវឱ្យមានការដាំកូនកោងកាងឡើងវិញឡើយ ប៉ុន្តែទាមទារឱ្យមានការរក្សាលំហូរទឹកត្រឹមត្រូវ។ ខុសពីមធ្យោបាយស្តារព្រៃកោងកាងកន្លងមក ការស្តារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងដោយផ្អែកលើសហគមន៍ទាមទារឱ្យអនុវត្តតាមដំណើរការបែបធម្មជាតិ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើប្រព័ន្ធអេកូឡូស៊ី និងជីវសាស្ត្រព្រៃកោងកាងនៅក្នុងតំបន់រិចរឹល។ CBEMR អនុញ្ញាតិឱ្យសហគមន៍សិក្សាពីបញ្ហាប្រឈមផ្នែកសង្គមនិងបច្ចេកទេសដែលប៉ះពាល់ដល់តំបន់ព្រៃកោងកាង ដោយរួមមានសិក្សាពីបញ្ហាប្រឈមផ្នែកជលសាស្ត្រ សិក្សាពីកម្ពស់ដីធៀបនឹងកម្រិតទឹកសមុទ្រ សិក្សាពីសម្ពាធលើដើមកោងកាង និងមូលហេតុដែលគេមិនអាចស្តារកោងកាងឡើងវិញតាមធម្មជាតិបាន។ CBEMR ត្រូវបានគេចាត់ទុកថាជាវិធីសាស្ត្រចំណាយមានប្រសិទ្ធភាព ដោយសារវាមិនត្រឹមតែជួយឱ្យទទួលបានជោគជ័យក្នុងការធ្វើឱ្យមានអត្រានៅរស់ខ្ពស់របស់ដើមកោងកាងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យជៀសវាងបាននូវការចំណាយមិនចាំបាច់នានា ដូចជាការរៀបចំថ្នាល និងការដាំកូនកោងកាងជាដើម [៤៣,៤៤]។

ដោយផ្អែកតាមបទពិសោធន៍ជាក់ស្តែងរបស់ប្រទេសថៃ កម្មវិធីស្តារឡើងវិញដែលពឹងផ្អែកលើមូលនិធិភ្នាក់ងារខាងក្រៅអាចបង្កផលប៉ះពាល់ដល់ស្វ័យភាពនៃស្ថាប័នផ្ទៃក្នុងក្នុងការសម្រេចចិត្តដូចជា ថាតើគួរដាំព្រៃកោងកាងដោយរបៀបណា នៅកន្លែងណា និងនៅពេលណា ដើម្បីឱ្យអត្រានៅរស់របស់ព្រៃកោងកាងមានកម្រិតខ្ពស់[៣៧]។ ឯកសារមួយចំនួនក៏បានបញ្ជាក់ថា កម្មវិធីស្តារព្រៃកោងកាងប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានភាពច្បាស់លាស់ក្នុងការចាត់ចែងសិទ្ធិកាន់កាប់ព្រៃកោងកាង។ តាមបទពិសោធន៍របស់ប្រទេសឥណ្ឌូនេស៊ី បើប្រៀបធៀបជាមួយរបៀបគ្រប់គ្រងផ្សេងៗ ការគ្រប់គ្រងដោយសហគមន៍ គឺផ្តល់ប្រសិទ្ធភាពខ្ពស់បំផុតក្នុងការគ្រប់គ្រង ការពារ និងស្តារឡើងវិញនូវព្រៃកោងកាង [៣០]។

## ៧. សេចក្តីសន្និដ្ឋាន និងបទពិសោធន៍ល្អៗ

ឯកសារស្រាវជ្រាវនេះបញ្ជាក់ថា កត្តាធម្មជាតិបានរួមចំណែកដល់ការបាត់បង់ព្រៃកោងកាង ប៉ុន្តែបញ្ហាជាប្រព័ន្ធក្នុងកិច្ចការអភិបាលកិច្ចព្រៃកោងកាង នៅតែជាកត្តាជំរុញដ៏សំខាន់ដែលត្រូវដោះស្រាយ។ តាមរយៈបទពិសោធន៍នៃប្រទេសកម្ពុជា ថៃ និងឥណ្ឌូនេស៊ី បញ្ហាអភិបាលកិច្ច ដែលជំរុញឱ្យមានការបាត់បង់ព្រៃកោងកាង និងបង្កជាជម្លោះនៅក្នុងប្រទេសទាំងបី រួមមាន៖ ភាពមិនច្បាស់លាស់លើសិទ្ធិកាន់កាប់និងផែនការប្រើប្រាស់ព្រៃកោងកាង ការអនុវត្តច្បាប់នៅមានកម្រិត ការសម្របសម្រួលអន្តរវិស័យពុំសូវមានប្រសិទ្ធភាព និងកង្វះការចូលរួមពីសហគមន៍។ ឯកសារនេះនឹងផ្តល់នូវបទពិសោធន៍ល្អៗមួយចំនួនសម្រាប់កិច្ចការពារព្រៃកោងកាងក្នុងតំបន់ប្រកបដោយប្រសិទ្ធភាព៖

- នៅក្នុងប្រទេសដែលផ្ទៃដីព្រៃកោងកាងស្ថិតនៅក្នុងតំបន់ការពារធម្មជាតិនៅមានវិសាលភាពតិចនៅឡើយ ការដាក់បញ្ចូលព្រៃកោងកាងឱ្យកាន់តែច្រើនទៅក្នុងតំបន់ការពារធម្មជាតិ គឺជាវិធានការចាំបាច់មួយ ដើម្បីគាំទ្រដល់កិច្ចការពារព្រៃកោងកាង។
- ការដាក់បញ្ចូលព្រៃកោងកាងទៅក្នុងតំបន់ការពារធម្មជាតិ អាចនឹងមិនសូវមានប្រសិទ្ធភាពក្នុងការការពារព្រៃកោងកាង ប្រសិនបើការកំណត់និងបែងចែកតំបន់ការពារធម្មជាតិធ្វើឡើងមិនបានច្បាស់លាស់ ឬ ការពង្រឹងការអនុវត្តច្បាប់ពុំមានប្រសិទ្ធភាព។
- ការពង្រឹងសុវត្ថិភាពលើសិទ្ធិកាន់កាប់ និងផែនការប្រើប្រាស់ដីព្រៃកោងកាង គឺមានសារៈសំខាន់ផងដែរក្នុងការជម្រុញឱ្យប្រជាពលរដ្ឋចូលរួមក្នុងការការពារ និងស្តារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងនៅក្នុងតំបន់ របស់ពួកគាត់ឡើងវិញ។ បន្ថែមលើនេះ ការផ្តល់សិទ្ធិកាន់កាប់ព្រៃកោងកាងសម្រាប់គម្រោងវិនិយោគខ្នាតធំ ដែលគំរាមកំហែងដល់សិទ្ធិរបស់សហគមន៍មូលដ្ឋាន គួរតែត្រូវបានជៀសវាង ឬតម្រូវឱ្យមានការអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថានសមស្របជាមុនសិន។
- ការការពារ និងការស្តារព្រៃកោងកាងប្រកបដោយប្រសិទ្ធភាព នៅតែស្ថិតនៅលើគំរូនៃការផ្តល់សិទ្ធិអំណាចនិងសិទ្ធិលក្ខណៈប្រពៃណីដល់សហគមន៍។ ដូច្នេះការប្រគល់សិទ្ធិគ្រប់គ្រងព្រៃកោងកាងដល់សហគមន៍ ដើម្បីការពារនិងស្តារឡើងវិញព្រៃកោងកាង គួរត្រូវបានគេពិចារណា។
- បណ្តាអ្នកពាក់ព័ន្ធ ត្រូវផ្តល់ការគាំទ្រដល់សហគមន៍ តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំដល់សហគមន៍ ការផ្តល់ការគាំទ្រលើបច្ចេកវិទ្យានិងធនធាន ការលើកកម្ពស់ការចូលរួម និងការជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋថ្នាក់មូលដ្ឋាន និងការធានាថា រដ្ឋាភិបាលអាចជួយសម្របសម្រួលក្នុងការគាំទ្រសហគមន៍។
- ខណៈប្រទេសនានាបានអនុម័តច្បាប់ និងគោលនយោបាយ ក្នុងការចូលរួមចំណែកកំណត់សិទ្ធិកាន់កាប់ព្រៃកោងកាង (ឧទាហរណ៍ តាមរយៈច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីឆ្នេរសមុទ្រ ច្បាប់ស្តីពីធនធានធម្មជាតិ ឬច្បាប់ភូមិបាល) គេរកឃើញថា ភាពត្រួតគ្នារវាងបទបញ្ញត្តិនៅតែបន្ត

មាន។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ចាំបាច់ត្រូវពិនិត្យសារឡើងវិញនូវច្បាប់ដែលមានស្រាប់ទាំងនោះ ដើម្បីបន្សុី និងកំណត់ឱ្យច្បាស់ពីដែនសមត្ថកិច្ចរបស់ស្ថាប័នដែលពាក់ព័ន្ធ។

- ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ដូច្នេះការកសាងភាពធន់ព្រៃកោងកាងតាមរយៈកម្មវិធីស្តារព្រៃកោងកាងឡើងវិញ គឺមានសារៈសំខាន់ណាស់។ កម្មវិធីស្តារព្រៃកោងកាងឡើងវិញ គួរផ្តោតលើការជ្រើសរើសប្រភេទពូជព្រៃកោងកាងសម្រាប់ការដាំដុះឱ្យបានត្រឹមត្រូវ និងត្រូវមានការគិតគូរទៅលើការងារជលសាស្រ្តក្នុងការគ្រប់គ្រងលំហូរទឹកសមុទ្រ ការចូលរួមរបស់សហគមន៍ក្នុងការថែទាំ ការផ្តល់មូលនិធិប្រកបដោយចីរភាព និងការផ្តល់ស្វ័យភាពដល់ស្ថាប័នក្នុងការសម្រេចចិត្តជ្រើសរើសវិធីសាស្រ្ត ទីកន្លែង និងពេលវេលាក្នុងការដាំ។

## ឯកសារយោង


[១] Leal, Maricé and Spalding, Mark D (editors) (2022). The State of the World's Mangroves 2022.

[២] RECOFTC (2011). Mangroves more Carbon Rich and Important for Climate Change. Available at: https://archive.recoftc.org/project/grassroots-capacity-building-redd/news-and-features/mangroves-more-carbon-rich-and-important-climate-change

[៣] P. Menéndez, I.J. Losada, S. Torres-Ortega, S. Narayan, M.W. Beck (2020). The Global Flood Protection Benefits of Mangroves, Scientific Reports 10 (1).

[៤] World Bank (2003). Governance of natural resources in the Philippines: Lessons from the past, direction.

[៥] Bunting, P.; Rosenqvist, A.; Hilarides, L.; Lucas, R.M.; Thomas, T.; Tadono, T.; Worthington, T.A.; Spalding, M.; Murray, N.J.; Rebelo, L-M. (2022). Global Mangrove Extent Change 1996 – 2020: Global Mangrove Watch Version 3.0. Remote Sensing. https://www.globalmangrovewatch.org/

[៦] Kusmana, C. and Sukristijiono, S. (2016). Mangrove Resource Uses by Local Community in Indonesia. Journal of Natural Resources and Environmental Management, vol. 6 (2).

[៧] World Bank (2021). Indonesia's 'Green Belt' - Mangroves for local and global benefits. Available at: https://blogs.worldbank.org/eastasiapacific/indonesias-green-belt-mangroves-local-and-global-benefits

[៨] Nop, S., DasGupta, R., Shaw, R. (2017). Opportunities and challenges for participatory management of mangroves resource (PMMR) in Cambodia. In: DasGupta, R., Shaw, R. (Eds.), Participatory Mangrove Management in a Changing Climate, Disaster and Risk Reduction, pp. 187–202. https://doi.org/10.1007/978-4-431-56481-2_12.

[៩] Kaosa-ard, M. and Pednekar, S.S. (1998) Background report for the Thai Marine Rehabilitation Plan 1997–2001. Report submitted to the Joint Research Centre of the Commission of the European Community and the Department of Fisheries, Ministry of Agriculture and Cooperatives, Thailand Development Research Institute, Bangkok, Thailand.

[១០] Spalding, M., Kainuma, M. and Collins, L. 2010. World Atlas of Mangroves. Earthscan, London.

[១១] Miller M.A. and Tonoto, P. (2023). Leveraging plural valuations of mangroves for climate interventions in Indonesia. Sustainability science 18:1533-1547.

[១២] MoE (2020). Cambodia forest cover 2018. Phnom Penh: MoE.

[១៣] FAO (2007). The world's mangroves 1980-2005. FAO forestry paper 153. Available at https://www.fao.org/3/a1427e/a1427e00.htm

[១៤] Veettil, B.K and Quang, N.X. (2019). Mangrove forests of Cambodia: Recent changes and future threats. *Ocean and coastal management*, 181(104895).

[១៥] Pumijumnong, N. (2014). Mangrove forests in Thailand. In Fraidah-Hanum, I., Latiff, A., Hakeem,

[១៦] Ei Win, Hnin (2018). Mangrove forest conservation in Thailand. https://ap.fftc.org.tw/article/1277

[១៧] IUCN (2020). Thailand celebrates its first National Mangrove Forest Day. Available at: https://www.iucn.org/news/thailand/202005/thailand-celebrates-its-first-national-mangrove-forest-day

[១៨] Fauzi, A. Sakti, A., Yayusman, L., Harto, A., Prasetyo, L., Irawan, B., Kamal, M. & Wikantika, K. (2019). Contextualizing mangrove forest deforestation in Southeast Asia using environmental and socio-economic data products. Forests, 10, 952.

[១៩] Richards, D.R. and Friess, D.A. (2016). Rates and drivers of mangrove deforestation in Southeast Asia, 2000–2012. PNAS: 113 (2) 344-349

[២០] Goldberg, L., Lagomasino, D., Thomas, N., and Fatoyinbo, T. (2020). Global declines in human-driven mangrove loss.

[២១] Su, J. (2021). Mapping mangrove in Cambodia: Evaluating mangrove forest land cover changes in Kampong Som Bay, Cambodia, using Landsat 8 OLI satellite data. https://storymaps.arcgis.com/stories/7949763f7c804cc88100d4237badd777

[២២] Ministry of Environment (Cambodia). 2019. National state of oceans and Coasts 2018: Blue Economy Growth of Cambodia. Partnerships in Environmental Management for the Seas of East Asia (PEMSEA), Quezon City, Philippines. 169 p.

[២៣] Ilman, M., Dargusch, P., Dart, P., and Onrizal. (2016). A historical analysis of the drivers of loss and degradation of Indonesia’s mangroves. *Land Use Policy.* 54:448-459.

[២៤] Arifanti, V.B.; Sidik, F.;Mulyanto, B.; Susilowati, A.;Wahyuni, T.; S.; Y.; Yuniarti, N.;Aminah, A.; Suita, E.; et al. (2022). Challenges and Strategies for Sustainable Mangrove Management in Indonesia: A Review. Forests, 13, 695. doi:https://doi.org/10.3390/f13050695

[២៥] Bhowmilk, A.K., Padmanaban, R., Cabral, P., and Romeiras, M.M. (2022). Global Mangrove Deforestation and Its Interacting Social-Ecological Drivers: A Systematic Review and Synthesis. Sustainability 2022, 14(8), 4433

[២៦] MAFF (2015). The strategic planning framework for fisheries update for 2015-2025. Phnom Penh: RGC

[២៧] RTG (2012). 11th National Economic and Social Development Plan (NESDP) (2012-2016). Bangkok: RTG.

[២៨] World Bank (2021). Indonesia's 'Green Belt' - Mangroves for local and global benefits. Available at: https://blogs.worldbank.org/eastasiapacific/indonesias-green-belt-mangroves-local-and-global-benefits

[២៩] FAO and IUCN (2016). Mangrove related policy and institutional frameworks in Pakistan, Thailand and Viet Nam.

[៣០] Banjade, M.R., Liswanti, N., Herawati, T., & Mwangi, E. (2017). Governing mangroves: Unique challenges for managing Indonesia's coastal forests. Bogor, Indonesia: CIFOR; Washington, DC: USAID Tenure and Global Climate Change Program.

[៣១] RGC (2012). Sub-degree on organization and Functioning of General Secretariat of National Committee On Coastal Area Management and Development. Phnom Penh, Cambodia

[៣២] RTG (2017). 12th National Economic and Social Development Plan (NESDP) (2017-2021). Bangkok: RTG.

[៣៣] Mursyid, H. et al. (2021). Governance issues related to the management and conservation of mangrove ecosystems to support climate change mitigation actions in Indonesia. Forest Policy and Economics 133. Available at: https://www.ykan.or.id/content/dam/tnc/nature/en/documents/ykan/buku-dan-jurnal/itp/1-s2.0-S1389934121002288-main.pdf

[៣៤] RGC (2001). Land Law. Phnom Penh, Cambodia.

[៣៥] Republic of Indonesia (2018). Amendment to Law Number 27 of 2007 on management of coastal zone and small island. Available at: https://faolex.fao.org/docs/pdf/ins139269.pdf

[៣៦] Pham TT, Vu TP, Pham DC, Dao LHT, Nguyen VT, Hoang NVH, Hoang TL, Dao TLC and Nguyen DT. 2019. Opportunities and challenges for mangrove management in Vietnam: Lessons learned from Thai Binh, Quang Ninh and Thanh Hoa provinces. Occasional Paper 197. Bogor, Indonesia: CIFOR.

[៣៧] Memon, J.A and Chandio, A.A. (2011). Critical appreciation of restoration and conservation of degraded mangroves in Thailand. *International Journal of Environmental and Rural Development* 2-2.

[៣៨] Jong, H. N. (2022, Feb 01). Indonesia on track with peatland restoration, but bogged down with mangroves. (Mongabay News) Retrieved Jul 20, 2023, from bogged-down-with-mangroves

[៣៩] Springer, J., Campese, J. and Nakangu, B. (2021). *The Natural Resource Governance Framework – Improving governance for equitable and effective conservation*. Gland, Switzerland: IUCN.

[៤០] Chigbu, U.E., Mabakeng, M.R. and Chilombo, A. 2021. Strengthening tenure and resource rights for land restoration. UNCCD Global Land Outlook Working Paper. Bonn.

[៤១] Rotich, B., Mwangi, E. and Lawry, S. (2016). Where land meets the sea: A global review of the governance and tenure dimensions of coastal mangrove forests. Available at:

https://www.climatelinks.org/sites/default/files/asset/document/2021-08/Where%20Land%20Meets%20the%20Sea%20Brief.pdf

[๔๒] McLeod, Elizabeth and Salm, Rodney V. (2006). Managing Mangroves for Resilience to Climate Change. IUCN, Gland, Switzerland. 64pp.

[๔๓] MAP (2024). Thailand’s mangrove reimagined Available at: https://photography.mangroveactionproject.org/stories-post/thailand-mangroves-reimagined

[๔๔] GMA (2024). Restoring the natural mangrove forest in Thailand. Available at: https://www.mangrovealliance.org/restoring-the-natural-mangrove-forest-in-thailand/#

# ឧបសម្ព័ន្ធ

| | | ស្ថាប័នទទួលខុសត្រូវ | យុត្តាធិការ |
|---|---|---|---|
| ក្រសួងគាំទ្រ | កម្ពុជា | រដ្ឋបាលជលផល ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | គ្រប់គ្រងធនធានជលផល រួមទាំងព្រៃកោងកាងនៅក្នុងតំបន់ព្រៃលិចទឹក ជាប់នឹងតំបន់នេសាទ |
| | | រដ្ឋបាលការពារ និងអភិរក្ស ធម្មជាតិ ក្រោមក្រសួងបរិស្ថាន | អនុវត្តក្របខណ្ឌសម្រាប់ ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ តំបន់ការពារធម្មជាតិ រួមបញ្ចូលទាំងធនធានជលផល និងព្រៃកោងកាង |
| | | | ស៊ើបអង្កេត ត្រួតពិនិត្យ និងបង្ក្រាប សកម្មភាពខុសច្បាប់ ដែលបង្កផលប៉ះពាល់ដល់តំបន់ការពារធម្មជាតិ បើចាំបាច់ ដាក់ពាក្យបណ្តឹងទៅតុលាការ |
| | ថៃ | នាយកដ្ឋាន ធនធានតំបន់ឆ្នេរ និងសមុទ្រ ក្រោមក្រសួងធនធានធម្មជាតិ និងបរិស្ថាន | គ្រប់គ្រងព្រៃកោងកាង នៅក្រៅឧទ្យានជាតិ និងតំបន់កងទ័ពជើងទឹក រួមបញ្ចូលទាំងព្រៃកោងកាងនៅក្នុងតំបន់អភិរក្ស និងព្រៃបម្រុង |
| | | នាយកដ្ឋាន អភិរក្ស ឧទ្យានជាតិ សត្វព្រៃ និងរុក្ខជាតិ ក្រោមក្រសួងធនធានធម្មជាតិ និងបរិស្ថាន | ត្រួតពិនិត្យព្រៃកោងកាង ក្នុងតំបន់ការពារធម្មជាតិ |
| | | កងទ័ពជើងទឹកថៃ | ត្រួតពិនិត្យព្រៃកោងកាងក្នុងមូលដ្ឋានទ័ពជើងទឹក |
| | វៀតណាម | ក្រសួងបរិស្ថាន និងព្រៃឈើ | ការពារព្រៃកោងកាង ដែលស្ថិតនៅក្នុងតំបន់ព្រៃរដ្ឋ ទាំងនៅលើដីគោក និងក្នុងដែនសមុទ្រ |
| | | ក្រសួង កិច្ចការសមុទ្រ និងនេសាទ | ការពារព្រៃកោងកាង នៅក្រៅតំបន់ព្រៃរដ្ឋ (តំបន់ឆ្នេរ និងតំបន់កោះតូចៗ) |
| | | ក្រសួង កិច្ចការកសិកម្ម និងផែនការទីតាំងក្នុងលំហ | អនុវត្តសិទ្ធិកាន់កាប់ និងអភិវឌ្ឍផែនការទីតាំងលំហក្នុងតំបន់ព្រៃកោងកាង |
| | | ក្រសួងផែនការអភិវឌ្ឍន៍ជាតិ | រៀបចំយុទ្ធសាស្ត្រជាតិ សម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង |
| ស្ថាប័នអន្តរក្រសួង | កម្ពុជា | គណៈកម្មាធិការជាតិ គ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរក្រោមក្រសួងបរិស្ថាន | ដោះស្រាយបញ្ហា ពហុវិស័យពាក់ព័ន្ធនឹងបញ្ហាធន ធានតំបន់ឆ្នេរ |
| | | គណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា២០១២ | គ្រប់គ្រង និងអភិវឌ្ឍ តំបន់ឆ្នេរក្នុងប្រទេសកម្ពុជាប្រកបដោយចីរភាព និងការទទួលខុសត្រូវ |

| | | |
|---|---|---|
| | គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ២០១៦ | ចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិដូចជា ការកាប់ព្រៃឈើ ការដឹកឈើនិងការនាំចេញឈើខុសច្បាប់ ការចាប់សត្វព្រៃ និងការនាំចេញសត្វព្រៃខុសច្បាប់ ការកាប់ទន្រ្ទានយកដីរដ្ឋ ព្រមទាំងការរ៉ុករករ៉ែដោយខុសច្បាប់នៅទូទាំងប្រទេស |
| ថៃ | គណៈកម្មាធិការជាតិ ស្តីពីគោលនយោបាយ និងផែនការ គ្រប់គ្រងធនធានតំបន់ឆ្នេរ និងសមុទ្រ | តាមដាន អនុវត្ត និងអនុម័ត គោលនយោបាយ អភិរក្សព្រៃកោងកាងថ្នាក់ជាតិ និងអនុវត្តផែនការទាក់ទងនឹងធនធានព្រៃកោងកាងទាំងឡាយ ដែលនៅក្រៅឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ហាមឃាត់ និងដីព្រៃកោងកាងឯកជន |
| ឥណ្ឌូនេស៊ី | ក្រុមសម្របសម្រួលជាតិ សម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង<br>ក្រុមសម្របសម្រួល យុទ្ធសាស្រ្តសម្រាប់ការគ្រប់គ្រង ដីសើម ក្រោមក្រសួងផែនការអភិវឌ្ឍន៍ជាតិ | ធានាឱ្យបាននូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពអន្តរជាតិ (SDGs) ការអភិវឌ្ឍន៍កាបូនទាប និងរបាយការណ៍ ការចូលរួមចំណែកដើម្បីអនុវត្ត អនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីការប្រែប្រួលអាកាសធាតុចំពោះអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) |